## ៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

រាជធានីភ្នំពេញ . ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០០១

## ប្រកាស

### ប្រកាសលេខ ១២៤ ស.ក.ប.យ

### ស្តីពីការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្ម

**រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច**
**ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែ មិនា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការងារ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៦ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញអនុក្រឹត្យលេខ ៨៧ អនក្រ.បក ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

-បានឃើញស្មារតីនៃអង្គប្រជុំគណៈកម្មការប្រឹក្សាការងារ

## សំរេច

**ប្រការ ១** : និយោជក នៃសហគ្រាស គ្រឹះស្ថាន ដូចមានចែងក្នុង មាត្រា ១ នៃច្បាប់ស្តីពីការងារ ត្រូវយកចិត្តទុកដាក់វិធានការធ្វោបាយចាំបាច់ ដើម្បីជៀសវាងកុំអោយការលើកដាក់ទម្ងន់មានគ្រោះថ្នាក់ដល់សុខភាពកម្មករនិយោជិត ពិសេសកុំអោយមានការប៉ះពាល់ដល់ឆ្អឹងខ្នង ។

ក្នុងករណីដែលការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្មផ្ទាល់មិនអាចជៀសវាងបានទេ ត្រូវធ្វើយ៉ាងណាកុំអោយការងារទាំងនោះបង្កគ្រោះថ្នាក់ដល់សុខភាពកម្មករនិយោជិត ។

ការលើកដាក់ទម្ងន់ សំរាប់កម្មករនិយោជិតម្នាក់ ឬច្រើននាក់ ជាអាទិ៍ :

-ការលើក

-ការដឹកនាំ

-ការដាក់ចុះ

-ការរុញ

-ការអូសទាញ

-ការរំកិល វត្ថុ ដែលមានទម្ងន់ដោយបញ្ចេញកម្លាំពលកម្មផ្ទាល់ ។

**ប្រការ ២** : ដើម្បីជាវិធានការល្អក្នុងការលើកដាក់ទម្ងន់ដោយកម្លាំងពលកម្មផ្ទាល់នេះ និយោជកត្រូវ :

-រៀបចំកញ្ចប់ទម្ងន់នីមួយៗកុំអោយទើសទែងនិងមិនលើសពី ៥០ គីឡូក្រាម

-រៀបចំផ្លូវឆ្លងកាត់អោយបានជិតបំផុតនិងមិនយ៉ាប់ធ្វើដំណើរ

-រៀបចំកម្មករនិយោជិតដែលចូលរួមធ្វើការលើកដាក់ទម្ងន់ដោយមិនបង្ខិតបង្ខំ

-រិះរកមធ្យោបាយបច្ចេកទេសជំនួយក្នុងការលើកដាក់ទម្ងន់

-ផ្តល់ដល់កម្មករនិយោជិតនូវការអប់រំបច្ចេកទេសលើកដាក់ទម្ងន់

**ប្រការ ៣** : ស្ត្រីមានផ្ទៃពោះ ឬស្ត្រីទើបចូលធ្វើការឡើងវិញបន្ទាប់ពីសំរាលកូន ឬរលូតកូន ឬរំលូតកូន ក្នុងរយៈពេល ២ ខែ ដំបូង មិនអនុញ្ញាតអោយលើកទម្ងន់លើសពី ៥គីឡូក្រាម

**ប្រការ ៤** : កម្មករនិយោជិតម្នាក់ មិនអនុញ្ញាតអោយ លើក ដាក់ អូស ទាញ រុញ ឬរំកិលទម្ងន់ ដោយកម្លាំងពលកម្មផ្ទាល់ ដែលមានចំនួនលើសពីទម្ងន់ដែលមានបង្ហាញក្នុងតារាងខាងក្រោមនេះ :

| សណ្ឋាននៃទម្ងន់ | បុរស | | ស្ត្រី | |
|---|---|---|---|---|
| | ចាប់ពី ១៥ ឆ្នាំ | ចាប់ពី ១៨ ឆ្នាំ | ចាប់ពី ១៥ ឆ្នាំ | ចាប់ពី ១៨ ឆ្នាំ |
| លើកដាក់ទម្ងន់ផ្ទាល់ | ១២គ.ក្រ | ៥០គ.ក្រ | ៦គ.ក្រ | ២៥គ.ក្រ |
| រទេះរុញកង់១ ផ្លូវក្នុងការដ្ឋាន | ៣២គ.ក្រ | ៨០គ.ក្រ | ហាម | ៤០គ.ក្រ |
| រទេះរុញកង់៣ឬ៤ ផ្លូវក្នុងការដ្ឋាន | ៤៨គ.ក្រ | ១២០គ.ក្រ | ២៤គ.ក្រ | ៦០គ.ក្រ |

ប្រការ ៥ : បទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស គ្រឹះស្ថាន អាចបញ្ជាក់ពីសេចក្តីច្បាស់លាស់នៃការរៀបចំការងារ លើកដាក់ទម្ងន់ ។ ក៏ប៉ុន្តែសេចក្តីបញ្ជាក់នៃបទបញ្ជាផ្ទៃក្នុងនេះ មិនអាចផ្ទុយពីប្រការទាំងឡាយ នៃប្រកាសនេះឡើយ ។

ប្រការ ៦ : ការមិនអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយនៃប្រកាសនេះ ត្រូវពិន័យ ឬទទួលទោស ដូចមានចែងក្នុង ជំពូកទី ១៦ នៃច្បាប់ស្តីពីការងារ ។

ប្រការ ៧ : ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**អ៊ិត សំហេង**

===

## ៤. ទីស្តីការរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០១

**ប្រកាស**

**ប្រកាសលេខ ១៩៦ ប្រក.សក.បធ**

**ស្តីពីការតែងតាំងមន្ត្រី រាជការ**

**រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច **នរោត្តម សីហនុ** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជាលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើត ក្រសួងសាធារណការនិងដឹកជញ្ជូន